# វេទិកាសិក្សាលើកទី ២

## ស្ដីពី

## ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន
## ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាព

**ថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ២០១៧ នៅសណ្ឋាគារកែបបេ ខេត្តកែប**

## លទ្ធផលលម្អិតនៃកិច្ចពិភាក្សាតាមក្រុមសម្រាប់ធ្វើការត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងខ្លួនឯងស្ដីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំ

**ក្រុមពិភាក្សា ជំពូកទី១៖ លក្ខណ:ផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន**

**១. តើអង្គការសហគមន៍មូលដ្ឋានក្នុងវិស័យអ្វី?**

សមាជិកក្រុម៖ **សហគមន៍ព្រៃកជ្រៃដើម្បីអភិវឌ្ឍន៍** ធ្វើការលើវិស័យដូចជា៖

- សន្សំប្រាក់
- សន្សំស្រូវ
- ធនាគារស្រូវ
- កសិកម្ម(បន្លែ និង ស្រូវ បរស)
- អាជីវកម្មខ្នាតតូច(រោង) របស់សហគមន៍

**២ .សូមប្រើប្រាស់បញ្ជីសំណួរ និងធ្វើការពិភាក្សាត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងខ្លួនឯងស្តីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អនៃ អង្គការសហគមន៍មូលដ្ឋាន ?**

**១- ដើម្បីបង្កើតសហគមន៍មូលដ្ឋានតើយើងត្រូវបង្កើលក្ខន្តិក:ដូចម្តេច?**

ដើម្បីបង្កើតសហគមន៍មួយយើងត្រូវបង្កើតលក្ខន្តិក:ដូចខាងក្រោម៖

- ប្រជុំជាមួយសមាជិកដើម្បីស្វែងរកបញ្ហា និងតម្រូវការរបស់សហគមន៍។
- បង្កើតគោលបំណង ទស្សន:វិស័យ
- បង្កើតលក្ខន្តិក: របស់សហគមន៍ (ក្រុមរោង សន្សំប្រាក់ សន្សំស្រូវ ធនាគារគោ គណ:កម្មការសមាជិក)។

**២- តើយើងគួរជ្រើសរើសគណ:កម្មការតាមរបៀបណា ?**

សហគមន៍ធ្វើការជ្រើសរើសគណ:កម្មការ ដោយធ្វើការបោះឆ្នោតពីសមាជិកដោយផ្អែកលើលក្ខន្តិក:របស់សហគមន៍។

**៣- តើដំណើរការបង្កើតអង្គកាសហគមន៍មូលដ្ឋានស្របតាមច្បាប់ដែលពាក់ព័ន្ធហើយឬនៅ ?**

សហគមន៍នេះមិនទាន់ចុះបញ្ជីនៅឡើយទេ។

**៤- ហេតុអ្វីបានយើងបង្កើតសហគមន៍មូលដ្ឋាន ?(គោលបំណងអ្វី?) ចង់ឃើញអ្វីនៅថ្ងៃអនាគត?**

គោលបំណងនៃការបង្កើតសហគមន៍គឺ ដើម្បីបង្កើនប្រាក់ចំណូលតាមរយៈ ផ្នែកទាំង៦ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍។

**៥- តើអ្វីខ្លះដែលសហគមន៍មូលដ្ឋានត្រូវប្រកាន់ខ្ជាប់ដើម្បីអោយគេជឿទុកចិត្ត ?**

ការប្រកាន់ខ្ជាប់របស់សហគមន៍ដើម្បីអោយមានការជឿទុកចិត្តរួមមាន៖

- តម្លាភាព
- មិនរើសអើង
- លើកកម្ពស់យេនឌ័រ

**៣ .តើក្នុងការអនុវត្តចំណុចសំខាន់ៗ នៃជំពូកនីមួយៗមានបញ្ហាប្រឈមអ្វីខ្លះ?**

បញ្ហាប្រឈមដែលសហគមន៍បានជួបប្រទះរួមមាន៖

- ពិបាកក្នុងការគៀងគរធនធានមនុស្ស
- អនុវត្តផែនកាមិនទាន់ពេលវេលា
- សមត្ថភាពក្នុងការសម្របសម្រួលរបស់សហគមន៍នៅមានកម្រិត។
- ការអនុវត្តមិនបានទៅតាមលក្ខន្តិកៈត្រឹមត្រូវ
- ការផ្សព្វផ្សាយព័ត៌មាននៅមានកម្រិត
- មានសមាជិកមួយចំនួនមិនសូវបានចូលរួម (អសកម្ម)
- ការគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិតព្រោះប្រព័ន្ធគ្រប់គ្រងមិនច្បាស់លាស់។
- មិនបានប្រើប្រាស់ប្រព័ន្ធក្នុងការវាយតម្លៃ ទៅលើការអនុវត្តច្បាស់លាស់។

**៤ .តើគួរធ្វើដូចម្តេចដើម្បីអោយការអនុវត្តរបស់អង្គការសហគមន៍មូលដ្ឋានកាន់តែមានប្រសិទ្ធិភាព?**

ដើម្បីអោយអង្គការសហគមន៍មូលដ្ឋានអនុវត្តការងារកាន់តែមានប្រសិទ្ធិភាពគួរមាន៖

- មានវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អ របស់សហគមន៍មូលដ្ឋាន ទៅដល់គណៈកម្មការ និងសមាជិក។
- ចូលរួមក្នុងការអនុវត្តន៍ ដឹកនាំ ត្រួតពិនិត្យនិងវាយតម្លៃ
- ពង្រឹងសមត្ថភាពទៅលើជំនាញផ្សេងៗទៅដល់គណៈកម្មការ និងសមាជិក

**ក្រុមពិភាក្សា ជំពូក២៖ ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ**

**១. តើអង្គការសហគមន៍មូលដ្ឋានក្នុងវិស័យអ្វី?**

- សហគមន៍នេសាទ
- សហគមន៍តំបន់ការពារធនធានធម្មជាតិ

- សហគមន៍ធនាគារគោ ប្រាក់សន្សំ និងធនាគារស្រូវ

**២ .សូមប្រើប្រាស់បញ្ជីសំណួរ និងធ្វើការពិនិត្យត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងខ្លួនឯងស្តីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អនៃ អង្គការសហគមន៍មូលដ្ឋាន ?**

**១- តើសហគមន៍មានទំនាក់ទំនង ល្អជាមួយអាជ្ញាធរពាក់ព័ន្ធហើយឬនៅ?**

- អង្គការសហគមន៍ត្រូវមានទំនាក់ទំនងនិងកិច្ចសហការល្អទាំងក្នុង និងក្រៅសហគមន៍។
- អង្គការសហគមន៍មានទំនាក់ទំនងជាមួយអាជ្ញាធរ និងជំនាញ។

**២- តើគណៈកម្មការបានគោរព និងអនុវត្តស្របតាមតួនាទី និងភារៈកិច្ចរបស់ខ្លួនហើយឬនៅ?**

- គណៈកម្មការត្រូវមានតួនាទីច្បាស់លាស់
- គណៈកម្មការត្រូវតែគោរពអនុវត្តតាមតួនាទីរៀងៗខ្លួន

**៣- តើគណៈកម្មការបានប្រជុំតាមផែនការប្រជុំដែលបានកំណត់ឬទេ?**

- គណៈកម្មការរៀបចំផែនការរៀងរាល់មួយខែម្តង (ប្រជុំឆ្លុះបញ្ចាំងសកម្មភាពកន្លងមកនិងផែនការបន្ត)។
- គណៈកម្មការនិងសមាជិកចូលរួមគ្រប់សកម្មភាពនៅក្នុងសហគមន៍

**៤- តើគណៈកម្មការសហគមន៍ និងសមាជិកបានចូលរួមសហការគ្នាហើយឬនៅ?**

គណៈកម្មការសហគមន៍ និងសមាជិកបានចូលរួមសហការគ្នា។

**៥- តើសហគមន៍មានទំនាក់ទំនង ល្អជាមួយអាជ្ញាធរពាក់ព័ន្ធហើយឬនៅ?**

សហគមន៍មានទំនាក់ទំនងល្អជាមួយអាជ្ញាធរពាក់ព័ន្ធ។

**៦- តើសហគមន៍មានទំនាក់ទំនងជាមួយអង្គការដៃគូ និងភាគីពាក់ព័ន្ធផ្សេងៗទៀតឬទេ?**

សហគមន៍មានទំនាក់ទំនងជាមួយអង្គការដៃគូនិងភាគីពាក់ព័ន្ធផ្សេងៗ។

**៧- តើសហគមន៍បានចូលរួមជាសមាជិកបណ្តាញណាខ្លះ?**

សហគមន៍មានការចូលរួមជាសមាជិកបណ្តាញពីសហគមន៍មួយទៅសហគមន៍មួយទៀត

**៨- តើសហគមន៍មានរៀបចំទុកដាក់ឯកសារ ឬរបាយការណ៍ និងកំនត់ហេតុប្រជុំបានត្រឹមត្រូវឬទេ?**

សហគមន៍ត្រូវរៀបចំឯកសារ ឯកសារ និងរបាយការណ៍ និងកំណត់ហេតុប្រជុំអោយបានត្រឹមត្រូវ។

## ជំពូកទី៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក

**១- តើការចូលជាសមាជិកសហគមន៍មូលដ្ឋានជាតម្រូវការ ឬដោយស្ម័គ្រចិត្ត?**

ការចូលរួមរបស់សមាជិកសហគមន៍គឺដោយស្ម័គ្រចិត្ត(ដោយគ្មានការបង្ខិតបង្ខំ)។

**២- សមាជិកដែលឈរឈ្មោះជាបេក្ខជនត្រូវមានលក្ខណៈបែបណាខ្លះ ?**

សមាជិកដែលឈរឈ្មោះជាបេក្ខជនត្រូវមានទីលំនៅក្នុងសហាគមន៍ពិតប្រាកដត្រូវចេះអាន ចេះសរសេរ (គ្មានចំណាកស្រុក) និងជាបុគ្គលដែលទទួលបានការទុកចិត្តនៅក្នុងសហាគមន៍។

**៣- សមាជិកសហាគមន៍មានសិទ្ធិចូលរួមអនុវត្តការងារអ្វីខ្លះ?**

សមាជិកសហាគមន៍មានសិទ្ធិចូលរួមអនុវត្តន៍ និងបញ្ចេញមតិ លើកជាបញ្ហាដែលកើតឡើងនៅក្នុង សហាគមន៍។

**៤- តើសមាជិកមានសិទ្ធិ និងតួនាទីអ្វីខ្លះ ឬកំរិតណាខ្លះ?**

សមាជិកសហាគមន៍មានតួនាទីចូលរួមផ្តល់ព័ត៌មានដល់គណ:កម្មការ និងអាជ្ញាធរមានជំនាញ។

**៥- តើសមាជិកត្រូវគោរពតាមគោលការណ៍ និងលក្ខន្តិក:អ្វីខ្លះ?**

សមាជិកត្រូវគោរពគោលការណ៍ និងលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់សហាគមន៍។

**៦- តើសមាជិកចូលរួមសម្រេចចិត្តផ្អែកលើគោលការណ៍អ្វីខ្លះ?**

សមាជិករបស់សហាគមន៍ចូលរួមក្នុងការសម្រេចចិត្តពង្រីកសហាគមន៍ ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងការអភិវឌ្ឍន៍ផ្សេងៗ។

**៧- តើសហាគមន៍មូលដ្ឋានមានយុទ្ធសាស្រ្តអ្វីខ្លះក្នុងការគៀងគរធានធាន និងការចូលរួមជាសមាជិក?**

សហាគមន៍មូលដ្ឋានមានយុទ្ធសាស្រ្ត គៀងគរ ធនធាន និង សមាជិកភាព ជាពិសេសលំលើកកម្ពស់ការចូលរួមពី បុរស ស្រ្តី យុវជន កុមារ និងជនពិការ ចូលជាសមាជិករបស់សហាគមន៍។

**៨- តើសហាគមន៍មូលដ្ឋានត្រូវមានផែនការប្រជុំដែរឬទេ?ហេតុអ្វី ?**

សហាគមន៍មូលដ្ឋានត្រូវមានផែនការប្រជុំ ដើម្បីបានព័ត៌មាននិងរបាយការណ៍តាមភូមិនិមួយៗ ហើយបញ្ចូលក្នុងផែនការឃុំដើម្បីរកដំណោះស្រាយ ដល់សមាជិកក្នុងសហាគមន៍មូលដ្ឋាន។

**៣តើក្នុងការអនុវត្តចំណុចសំខាន់ៗ នៃជំពូកនីមួយៗមានបញ្ហាប្រឈម .អ្វីខ្លះ?**

- មានទំនាក់ទំនង តែគ្មានបណ្តាញ

**៤ .តើគួរធ្វើដូចម្តេចដើម្បីអោយការអនុវត្តរបស់អង្គការសហាគមន៍មូលដ្ឋានកាន់តែមានប្រសិទ្ធិភាព?**

- ស្វែងរកតាមអង្គការដៃគូដើម្បីទទួលបានវគ្គបណ្តុះបណ្តាល
- សំណូមពរអោយអង្គការគ.ស.ក និងអង្គការផ្សេងៗគាំទ្រដល់សហាគមន៍ ជំនាញ និងសេវាទំនាក់ទំនងដៃគូ។

## ជំពូកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ

**១- តើអង្គការសហាគមន៍មូលដ្ឋានក្នុងវិស័យអ្វីខ្លះ?**

  - សហាគមន៍នេសាទ (វិស័យជលផល)
  - សហាគមន៍តំបន់ការពារធនធានធម្មជាតិ

- ○ សហគមន៍ក្នុងវិស័យកសិកម្ម(ដាំបន្លែ និង ចិញ្ចឹមសត្វ)
- ○ សហគមន៍ព្រៃឈើ

**២- តើយើងធ្វើការគ្រប់គ្រងចំណូល ចំណាយ យ៉ាងដូចម្តេច ?**

សហគមន៍មូលដ្ឋានត្រូវធ្វើការគ្រប់គ្រងចំណូល ចំណាយតាមរយៈការប្រជុំរបស់គណៈកម្មការ។

**៣- មុនចំណាយតើអ្នកណាជាអ្នកសម្រេច?**

- ប្រធានសហគមន៍ជាអ្នកសម្រេចចិត្តមុនពេលចំណាយ។

**៤- តើការទុកដាក់ឯកសារចំណូល ចំណាយយ៉ាងដូចម្តេច?**

- រាល់ឯកសារចំណូល ចំណាយត្រូវរៀបចំដាក់ក្រូណូរ និងដាក់ក្នុងហិបនិងទូដែក។

**៥- តើមានអ្នកណាខ្លះជាអ្នកសម្រេចចិត្តក្នុងការចំណាយថវិការបស់សហគមន៍?**

អ្នកដែលមានសិទ្ធិចិត្តក្នុងការប្រើប្រាស់ថវិការបស់សហគមន៍មាន៤នាក់រួមមានៈ ប្រធាន អនុប្រធាន បេឡា និង ហិរញ្ញិក។

**៥- តើថវិកាកម្រិតណាត្រូវរក្សាទុកនៅធនាគារ?**

ថវិកាចំណួនចាប់ពីបួនលានរៀលឡើងទៅសហគមន៍ត្រូវរក្សាទុកក្នុងធនាគារ។

**៦- តើអ្នកណាជាអ្នករក្សាទុកថវិកា?**

អ្នកដែលរក្សាទុកថវិការបស់សហគមន៍រួមមានបេឡា និង ហិរញ្ញឹក។

**៧- តើពេលណាយើងត្រូវផ្សព្វផ្សាយពីថវិកាទៅដល់សមាជិកបានដឹង?**

យើងត្រូវផ្សព្វផ្សាយពីថវិកាទៅដល់សមាជិកបានដឹងតាមរយៈកិច្ចប្រជុំប្រចាំខែឬប្រជុំប្រចាំត្រីមាស។

**៨- តើការចំណាយត្រឹមត្រូវ ត្រូវមានអ្វីខ្លះ?**

ការចំណាយដែលទទួលជាចំណាយត្រឹមត្រូវគឺត្រូវមានវិក័យបត្រដែលមានគុណភាព។

**៩- តើគោលការណ៍ហិរញ្ញវត្ថុត្រូវទទួលស្គាល់ដោយថ្នាក់ណាដែរ?**

គោលការណ៍ហិរញ្ញវត្ថុត្រូវទទួលស្គាល់ដោយអាជ្ញាធរ ភូមិឃុំ។

**១០- តើយើងត្រូវបែងចែកភាគលាភដោយរបៀបណា?**

សហគមន៍ត្រូវបែងចែកភាគលាភដោយផ្នែក។

**១១- តើនិតិវិធីសន្សំប្រាក់ដោយរបៀបណា?**

និតិវិធីសន្សំប្រាក់គឺធ្វើឡើងតាមរយៈការសន្សំប្រាក់ដោយការចងក្រងជាក្រុម គោរពតាមបទបញ្ជាផ្ទៃក្នុង។

**១២- តើដំណើរការ ខ្ចី និងសងប្រាក់ប្រព្រឹត្តិយ៉ាងដូចម្តេចដែរ?**

ដំណើរការខ្ចី និង សងប្រាក់ត្រូវគោរពតាមលក្ខន្តិកៈរបស់ក្រុម។

**១៣- តើដំណើរការរៀបចំផែនការចំណូលនិងចំណាយធ្វើទៅយ៉ាងដូចម្តេចដែរ?**

ចំណូលនិងចំណាយត្រូវមានបញ្ជីស្នាមច្បាស់លាស់។

**១៤- តើចំណូល ចំណាយពីប្រភពណាខ្លះដែរត្រូវធ្វើរបាយការណ៍?**

បដិភាគសមាជិកសហគមន៍ សប្បុរជន អង្គការដៃគូ។

**១៥- តើពេលណាដែលសហគមន៍ត្រូវកំណត់ធ្វើសវនកម្មពីការគ្រប់គ្រងបញ្ជីចំណូលចំណាយ? ហើយការធ្វើ សវនកម្មនេះត្រូវធ្វើឡើងដោយអ្នកខាងក្នុង ឬអ្នកខាងក្រៅ ?**

សហគមន៍ត្រូវធ្វើសវកម្មលើការគ្រប់គ្រងបញ្ជីចំណូល ចំណាយរៀងរាល់ចុងឆ្នាំដោយ គណៈកម្មការ អាជ្ញាធរ និង អង្គការដៃគូ។

## ក្រុមពិភាក្សា ជំពូក៨៖ គណនេយ្យភាព និងតម្លាភាព

**១. តើអង្គការសហគមន៍មូលដ្ឋានក្នុងវិស័យអ្វី?**

- សហគមន៍ជនពិការ
- សហគមន៍នេសាទ
- សហគមន៍តំបន់ការពារធម្មជាតិ
- សហគមន៍បន្លែធម្មជាតិ
- ក្រុមសន្សំប្រាក់

**១- គណនេយ្យភាព មានការស្មោះត្រង់ តើធ្វើដូចម្តេចអោយមានការស្មោះត្រង់?**

រាល់ដំណាក់កាលនៃការបង្កើតគម្រោង ឬកម្មវិធីផ្សេងៗ គួរមានសមាជិក ឬប្រជាពលរដ្ឋ ឬអាជ្ញាធរចូលរួម។

**២- តើគួរធ្វើយ៉ាងណា  អោយមានគណនេយ្យភាព? តើគណនេយ្យភាពមានសារៈសំខាន់អ្វីខ្លះនៅក្នុងសហគមន៍?**

គណនេយ្យភាពគឺជាការលើកទឹកចិត្តសមាជិក និងប្រជាពលរដ្ឋក្នុង គោលដៅ ទទួលខុសត្រូវលើការអនុវត្តគម្រោង ឬកម្មវិធី ត្រួតពិនិត្យ និងធ្វើការវាយតម្លៃ

**៣-ដូចម្តេចដែលហៅថាតម្លាភាព? បើគ្មានតម្លាភាពតើប៉ះពាល់អ្វីខ្លះនៅសហគមន៍ទាំងមូល?  បើគ្មានតម្លាភាពតើសហគមន៍ដំណើរការបានល្អដែរឬទេ?**

តម្លាភាព ស្មោះត្រង់ សាមគ្គីភាព មានទំនុកចិត្ត នៅក្នុងសហគមន៍។ បើគ្មានតម្លាភាព សហគមន៍មិនដំណើរការបានល្អទេ។

**៤- តើអង្គការសហគមន៍មូលដ្ឋានមានគោលការណ៍ទំនាស់ផលប្រយោជន៍ដែរឬទេ?**

ត្រូវការបង្កើតគោលការណ៍ទំនាស់ផលប្រយោជន៍។

**៥- តើអង្គការសហគមន៍មូលដ្ឋានមានយន្តការផ្តល់ពត៌មានត្រលប់ និងបណ្តឹងដែរឬទេ?**

ត្រូវការបង្កើតយន្តការ ផ្តល់ព័ត៌មានត្រលប់ និងបណ្តឹង។

**ជំពូក៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ**

**១- តើសហាគមន៍របស់អ្នកមានផែនការប្រចាំឆ្នាំដែរឬទេ?**

សហាគមន៍មានផែនការប្រចាំឆ្នាំ

**២- តើផែនការប្រចាំឆ្នាំនោះធ្វើឡើងដោយមានការចូលរួមពីសមាជិកដែរឬទេ?**

ផែនការប្រចាំឆ្នាំត្រូវមានការចូលរួមពីសមាជិក។

**៤- តើផែនការវាយតម្លៃនោះជាប្រភេទការវាយតម្លៃ**

- **ខាងក្នុង ?**
- **ខាងក្រៅ?**

រាល់ការអនុវត្តផែនការត្រូវមានការត្រួតពិនិត្យ និងវាយតម្លៃ ខាងក្នុង និងខាងក្រៅ។

**៥- តើអ្នកយករបាយការណ៍ដែលបានរកឃើញតាមរយៈការតាមដាន និងត្រួតពិនិត្យទៅប្រើប្រាស់យ៉ាងដូចម្តេចខ្លះ?**
យករបាយការណ៍តាមដាន និងវាយតម្លៃសម្រាប់ធ្វើការអនុវត្តបន្ត និងកែសម្រួលថ្មី

**៣?តើក្នុងការអនុវត្តចំណុចសំខាន់ៗ នៃជំពូកនីមួយៗមានបញ្ហាប្រឈមអ្វីខ្លះ .**

- ខ្វះការចូលរួម ខ្វះចំណេះដឹង ការយល់ដឹង
- ពេលវេលា ក្នុងការចូលរួមមិនស្របគ្នា

**៤ .តើគួរធ្វើដូចម្តេចដើម្បីអោយការអនុវត្តរបស់អង្គការសហាគមន៍មូលដ្ឋានកាន់តែមានប្រសិទ្ធិភាព?**

ធ្វើអោយមានគណនេយ្យភាព តម្លាភាព ការចូលរួមអនុវត្ត និងត្រួតពិនិត្យ វាយតម្លៃ។

**ជំពូក៧៖ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព**

**១- តើអង្គការសហាគមន៍មូលដ្ឋានមានសន្និបាតដែរឬទេ?**

សហាគមន៍មូលដ្ឋានមានសន្និបាតប្រចាំឆ្នាំ

**២- តើអង្គការសហាគមន៍មូលដ្ឋានមានយុទ្ធសាស្ត្រយ៉ាងណាដើម្បីនិរន្តភាព? ៣- តើសហាគមន៍គួរមានប្រភេទសេវាកម្មអ្វីខ្លះដែលអាចរកប្រាក់ចំណូលបាន?**

សហាគមន៍មាននិរន្តរភាពត្រូវបង្កើតអោយបាន

- សេវាកម្មទេសចរណ៍

- ក្រុមចិញ្ចឹម និងដាំបន្លែ
- ផែនការដកហូតធនធានធម្មជាតិ
- ក្រុមកែច្នៃ
- ក្រុមសន្សំប្រាក់

**៤- តើសហាគមន៍ធ្លាប់បានបញ្ចូលផែនការទៅក្នុងផែនការវិនិយោគឃុំដែររឺទេ?**

សហាគមន៍ធ្លាប់បានបញ្ចូលផែនការទៅផែនការឃុំ ប៉ុន្តែមិនមានការគាំទ្រ

**៥- តើមានការត្រួតពិនិត្យសេវាកម្ម ឬផលិតផលក្នុងសហាគមន៍ដែរឬទេ?**

សហាគមន៍មានអាជ្ញាធរចុះពិនិត្យលើវិស័យទេសចរណ៍។

## ជំពូក ៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង

**១- តើគណៈកម្មការ និងសមាជិកអង្គការសហាគមន៍មូលដ្ឋានមានសមត្ថភាពគ្រប់គ្រាន់ហើយឬនៅ?**

គណៈកម្មការ និងសមាជិកមិនទាន់មានសមត្ថភាពលើការគ្រប់គ្រង

**២- តើអង្គការសហាគមន៍មូលដ្ឋានមានចំណេះ និងជំនាញក្នុងការសម្របសម្រួលកិច្ចប្រជុំ និង ផ្សព្វផ្សាយឬទេ?**

សហាគមន៍ខ្វះជំនាញសម្របសម្រួល និងផ្សព្វផ្សាយ

**៣- តើគណៈកម្មការមានចំណេះដឹងខាងផ្នែកទីផ្សារដែរឬទេ?**

គណៈកម្មការមានចំណេះដឹងផ្នែកទីផ្សារតិចតួច។

រៀបចំដោយ៖ កញ្ញា កៅ ពៅលក្ខិណា
អ្នកឯកទេសផ្នែកអង្គការសហាគមន៍មូលដ្ឋាន
លេខទូរស័ព្ទ៖ ០១២ ៨៧២ ០៥៣
អ៊ីមែល៖ peouleakhena.kao@ccc-cambodia.org
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា